NSW HEALTH

*ប័ណ្ណព័ត៌មានអំពីជំងឺឆ្លង*

# ជំងឺស្អូច

***ជំងឺស្អូចគឺបណ្តាលដោយការឆ្លងវីរុសមួយប្រភេទ។ ជាធម្មតាជំងឺនេះមានភាពមិនសូវធ្ងន់ធ្ងរទេ ប៉ុន្តែអាចបង្កការខូចខាតខ្លាំងក្លាដល់ទារកក្នុងផ្ទៃ។ ការចាក់ថ្នាំបង្ការរោគគួរធ្វើឡើងចំពោះកុមារទាំងអស់នៅពេលមានអាយុ 12 ខែ និង 4 ឆ្នាំ។ ស្ត្រីទាំងអស់ដែលគ្រោងមានផ្ទៃពោះ គួរឆែកមើលប្រព័ន្ធការពាររបស់ខ្លួនទល់នឹងរោគនេះសិន។***

**កែតំរូវចុងក្រោយ៖** ថ្ងៃទី 15 ខែមករា ឆ្នាំ 2008

## តើស្អូចគឺជាជំងឺអ្វី?

- ស្អូចគឺជាជំងឺឆ្លងមួយរបស់មនុស្សដែលបង្កដោយវីរុស។
- ទោះជាជំងឺនេះមានភាពមិនសូវធ្ងន់ធ្ងរចំពោះមនុស្សភាគច្រើនក្តី ក៏ការកើតមានជំងឺនេះនៅពេលមានផ្ទៃពោះថ្មីថ្មោងអាចបណ្តាលឲ្យមានគុណវិបត្តិធ្ងន់ធ្ងរចំពោះទារកក្នុងផ្ទៃ និងការរលូតកូន។

## តើស្ថានភាពជំងឺស្អូចពីកំណើត (congenital rubella syndrome) គឺជាអ្វី?

- ស្ថានភាពជំងឺស្អូចពីកំណើតកើតមានឡើងចំពោះទារកដល់ទៅ 90 ភាគរយ ដែលប្រសូតពីម្តាយដែលកើតជំងឺស្អូចក្នុងអំឡុងពេលមានផ្ទៃពោះបីខែដំបូង។
- ស្ថានភាពជំងឺស្អូចពីកំណើតអាចបណ្តាលឲ្យមានគុណវិបត្តិដល់ទារកក្នុងផ្ទៃ ដោយមានរួមទាំងបញ្ហាខូចបេះដូង ថ្លង់ ការខូចខាតខួរក្បាល និងបញ្ហាភ្នែក ដោយមានរួមទាំងភ្នែកឡើងបាយទៀតផង។

## តើជំងឺនេះមានរោគសញ្ញាអ្វីខ្លះ?

- រោគសញ្ញានៃជំងឺស្អូចអាចមានរួមទាំងគ្រុនក្តៅមិនសូវខ្លាំង កន្ទួល ហៀរសំបោរ ឈឺបំពង់ក និងជាញឹកញយហើមកូនកណ្តុរ។ ការឈឺសន្លាក់ក៏កើតមានជាទូទៅផងដែរ ជាពិសេសចំពោះស្ត្រី។
- នៅក្នុងករណីកំរ ការកើតជំងឺស្អូចអាចបង្កភាពស្មុគស្មាញដោយសារការធ្លាក់ចុះនូវកោសិកាឈាម (thrombocytopenia) ដែលអាចបណ្តាលឲ្យមានការចេញឈាម ឬការរលាកខួរក្បាល។

## តើជំងឺនេះឆ្លងតាមរបៀបណា?

- ស្អូចឆ្លងពីអ្នកកើតជំងឺនេះតាមរយៈចំហាយទឹកចេញពីច្រមុះឬមាត់ ឬតាមរយៈការប៉ះពាល់ដោយផ្ទាល់។ ជំងឺស្អូចឆ្លងយ៉ាងងាយទៅកាន់មនុស្សទាំងឡាយដែលមិនបានចាក់ថ្នាំ ឬមិនធ្លាប់កើតជំងឺនេះ។
- ជាធម្មតា រយៈពេលចាប់ពីពេលប៉ះពាល់នឹងមេរោគរហូតដល់ពេលកើតមានជំងឺគឺពី 14 ទៅ 21 ថ្ងៃ។ ជាធម្មតាអ្នកកើតស្អូចកើតមានជំងឺនេះចាប់ពីពេលប្រាំពីរថ្ងៃមុនពេលកន្ទួលកើតមានឡើង រហូតដល់ពេលបួនថ្ងៃក្រោយមកទៀត។

## តើអ្នកណាខ្លះដែលអាចមានគ្រោះថ្នាក់កើតជំងឺនេះ?

ជនរាល់រូបដែលមិនស៊ាំនឹងជំងឺនេះ (តាមរយៈការកើតមាននៅពេលកន្លងមក ឬការចាក់ថ្នាំបង្ការរោគ) មានគ្រោះថ្នាក់កើតជំងឺស្អូច។

## តើវិធីបង្ការជំងឺនេះធ្វើឡើងដោយរបៀបណា?

- អ្នកកើតស្អូចគួរស្នាក់នៅក្នុងផ្ទះរយៈពេលយ៉ាងតិចបួនថ្ងៃ ក្រោយពីចេញកន្ទួល និងចៀសវាងការប៉ះពាល់អ្នកដែលមិនស៊ាំនឹងជំងឺនេះ។
- វិធីការពារប្រសើរបំផុតទល់នឹងជំងឺស្អូចគឺតាមរយៈការចាក់ថ្នាំបង្ការរោគ MMR  ដែលការពារទល់នឹងការឆ្លងជំងឺកញ្ជ្រឹល សាទ្បាទែន និងស្អូច។
- ថ្នាំបង្ការរោគ MMR គួរចាក់ឲ្យកុមារនៅពេលមានអាយុ 12 ខែ និងនៅពេលមានអាយុបួនឆ្នាំ។ ថ្នាំ MMR ចំនួនពីរកំរិតផ្តល់ការការពារទល់នឹងជំងឺស្អូចចំពោះអ្នកចាក់ថ្នាំនេះដល់ទៅជាង 99 ភាគរយ។
- ថ្នាំបង្ការរោគ MMR ជាថ្នាំមានសុវត្ថិភាពនិងប្រសិទ្ធភាព ដែលប្រើទូទាំងពិភពលោកជាច្រើនឆ្នាំមកហើយ។
- នៅក្នុងពេលដែលជនពេញវ័យអាយុច្រើនយ៉ាងច្រើននាក់ស៊ាំនឹងជំងឺស្អូច ដោយសារតែអ្នកទាំងនោះបានចាក់ថ្នាំឬកើតរោគនេះនៅពេលនៅក្មេងក្តី  ក៏យុវជនពេញវ័យ (ជាពិសេសបុរស) អាចមិនស៊ាំនឹងជំងឺនេះដែរ។ ការចាក់ថ្នាំបង្ការរោគស្អូចមានសារសំខាន់ណាស់ចំពោះស្ត្រី(និងបុរស)ដែលមានអាយុអាចបង្កើតកូនបាន ដើម្បីកាត់បន្ថយឱកាសរបស់ស្ត្រីមានផ្ទៃពោះក្នុងការប៉ះពាល់និងកើតជំងឺស្អូច។
- ជាការសំខាន់ណាស់ដែលស្ត្រីទាំងអស់ដែលគ្រោងមានផ្ទៃពោះ ដឹងថាតើខ្លួនស៊ាំនឹងជំងឺស្អូចដែរឬទេ។ ស្ត្រីដែលគ្រោងមានផ្ទៃពោះគួរធ្វើតេស្តឈាម ដែលអាចធ្វើដោយវេជ្ជបណ្ឌិតក្នុងតំបន់របស់ខ្លួន ដើម្បីឆែកមើលថា តើខ្លួនស៊ាំនឹងជំងឺនេះដែរឬទេ។ ស្ត្រីមានផ្ទៃពោះមិនគួរចាក់ថ្នាំបង្ការរោគស្អូចទេ ហើយស្ត្រីគួរចៀសវាងការមានផ្ទៃពោះរយៈពេលមួយខែ ក្រោយពីបានចាក់ថ្នាំបង្ការរោគនេះហើយ។

## តើការវិនិច្ឆ័យរោគធ្វើទៅតាមរបៀបណា?

ជំងឺស្អូចអាចលំបាកធ្វើរោគវិនិច្ឆ័យ ដោយសារតែមានវីរុសច្រើនផ្សេងទៀតដែលបណ្តាលឲ្យមានជំងឺស្រដៀងគ្នា ដែលធ្វើឲ្យមានគ្រុនក្តៅនិងកន្ទួល ។ រោគវិនិច្ឆ័យច្បាស់លាស់តម្រូវឲ្យធ្វើតេស្តឈាម។

## តើវិធីព្យាបាលជំងឺនេះធ្វើឡើងដោយរបៀបណា?

ការព្យាបាលរោគសញ្ញានៃជំងឺស្អូចមានរួមទាំងការសំរាក និងការទទួលទានជាតិទឹកឲ្យបានច្រើន។

## តើផ្នែកសុខភាពសាធារណៈមានវិធានការឆ្លើយតបអ្វីខ្លះ?

ស្ត្រីមានផ្ទៃពោះដែលបានប៉ះពាល់អ្នកកើតស្អូចគួរទាក់ទងសុំឱវាទពីវេជ្ជបណ្ឌិតរបស់ខ្លួន។ នៅក្រោមច្បាប់សុខាភិបាលសាធារណៈ មន្ទីរពិសោធន៍ក្នុងរដ្ឋ NSW ត្រូវរាយការណ៍ឲ្យដឹងអំពីការកើតមានជំងឺនេះ។ ផ្នែកសុខភាពសាធារណៈតាមដានស្ថិតិចំនួនករណី ដើម្បីតាមពិនិត្យមើលឥទ្ធិពលនៃកម្មវិធីចាក់ថ្នាំបង្ការរោគ និងដើម្បីរកមើលដឹងការឆ្លងរាតត្បាតទាំងឡាយ។

## ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW

ដើម្បីទទួលព័ត៌មានបន្ថែម សូមទាក់ទងវេជ្ជបណ្ឌិត ផ្នែកសុខភាពសាធារណៈក្នុងតំបន់ ឬមណ្ឌលសុខភាពសហគមន៍របស់លោកអ្នក។ សូមរកមើលនៅក្រោមពាក្យ *NSW Government* នៅផ្នែកខាងមុខនៃសៀវភៅទូរស័ព្ទ White Pages ។

| តំបន់ទីក្រុង | ទីតាំង | លេខទូរស័ព្ទ | តំបន់ជនបទ | ទីតាំង | លេខទូរស័ព្ទ |
|---|---|---|---|---|---|
| **Northern Sydney/Central Coast** | Hornsby | 02 9477 9400 | **Greater Southern** | Goulburn | 02 4824 1837 |
| | Gosford | 02 4349 4845 | | Albury | 02 6080 8900 |
| **South Eastern Sydney/Illawarra** | Randwick | 02 9382 8333 | **Greater Western** | Broken Hill | 08 8080 1499 |
| | Wollongong | 02 4221 6700 | | Dubbo | 02 6841 5569 |
| **Sydney South West** | Camperdown | 02 9515 9420 | | Bathurst | 02 6339 5601 |
| **Sydney West** | Penrith | 02 4734 2022 | **Hunter/New England** | Newcastle | 02 4924 6477 |
| | Parramatta | 02 9840 3603 | | Tamworth | 02 6767 8630 |
| **Justice Health Service** | Matraville | 02 9311 2707 | **North Coast** | Port Macquarie | 02 6588 2750 |
| **NSW Department of Health** | Nth Sydney | 02 9391 9000 | | Lismore | 02 6620 7500 |
| **NSW Health: www.health.nsw.gov.au** | | | | | |